គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

**Tonle Sap Technology Demonstrations for Productivity Enhancement**

(TSTD - TA 7305-CAM)

# សៀវភៅណែនាំបច្ចេកទេសស្តីពី

# ផលិតកម្មស្រូវពូជ



ខែ សីហា ឆ្នាំ ២០១៣

# តារាងមាតិកា

១. សេចក្តីផ្តើម ........ 1

២. ផលិតកម្មស្រូវពូជ ........ 2
២-១. សម្ភារៈសម្រាប់ការងារផលិតកម្មស្រូវពូជ ........ 2
២-២. ពូជស្រូវដែលប្រើប្រាស់ ........ 1
២-៣. ការជ្រើសគ្រាប់ពេញ និងត្រាំផ្អាប់គ្រាប់ពូជ ........ 3
២-៤. ការរៀបចំថ្នាលសំណាប និងការសាប ........ 4
២-៥. ការដកសំណាប ........ 4
២-៦. ការរៀបចំដីស្រែ ........ 6
២-៧. ការស្ទូង ........ 6
២-៧-១. ការរៀបចំខ្សែខ្នាតស្ទូង ........ 6
២-៧-២. ការស្ទូងជាជួរ ........ 7
២-៨- ការប្រើប្រាស់ជី ........ 7
២-៨-១. ប្រភេទជី និងការប្រើប្រាស់ជី ........ 8
២-៨-២. ជីទ្រាប់បាត ........ 9
២-៨-៣. ជីបំប៉ន ........ 9
២-៩. ការថែទាំសន្ទូង និងការគ្រប់គ្រងទឹក ........ 10
២-១០. ការចុះកាត់ពូជលាយ ........ 10
២-១១. ការកំចាត់ស្មៅចង្រៃ ........ 11
២-១២. ការកំចាត់សត្វកណ្តុរ ........ 12
២-១៣. ការប្រមូលផល ........ 12
២-១៣-១ ប្រមូលផល ច្រូតកាត់ បោកបែនដោយដៃ ........ 13
២-១៣-២ ប្រមូលផល ច្រូតកាត់បោកបែនដោយគ្រឿងម៉ាស៊ីន ........ 13

៣- កិច្ចប្រតិបត្តិការខារបច្ចេកទេសក្រោយពេលប្រមូលផល ........ 14
៣-១. ការហាលសំងួត ........ 14
៣-២- ការបក់សំអាតគ្រាប់ ........ 15
៣-៣. ការច្រកខ្ចប់ ........ 15
៣-៤. ការទុកដាក់ ថែទាំគ្រាប់ពូជ ........ 16
៣-៥- វិធីយកសំណាកគ្រាប់ពូជ ........ 16

៣-៦- ការធ្វើតេស្តដំណុះ.......... 17
៣-៧- របៀបវាស់រកអត្រាសំណើមគ្រាប់.......... 17
៣-៨- ការដាក់ថ្នាំសម្លាប់សត្វល្អិតដែលស៊ីបំផ្លាញគ្រាប់ពូជនៅក្នុងបាវ.......... 18

៤- **គុណភាពស្រូវពូជ**.......... 19
៤-១- លក្ខណៈគុណភាពស្រូវពូជ.......... 19
៤-១-១- សំណើមគ្រាប់.......... 19
៤-១-២- ស្រូវពូជស្អាត.......... 20
៤-១-៣- ស្រូវពូជសុទ្ធ.......... 21
៤-១- ៤- គ្រាប់ប្រេះ ឬ ស្រាំ.......... 21
៤-១-៥- គ្រាប់ស្រូវនៅស្មើរ.......... 21
៤-១-៦- គ្រាប់ទទួលការបំផ្លាញដោយជម្ងឺ និងសត្វល្អិត.......... 21

៤-២- កម្រិតស្តង់ដាគុណភាពគ្រាប់ពូជ.......... 21

៥. **ការផ្សព្វផ្សាយលទ្ធផលធ្វើបង្ហាញ ផលិតកម្មស្រូវពូជ**.......... 21

៦. **ការកត់ត្រាចំណាយចំណូលផលិតកម្ម និង វិភាគសេដ្ឋកិច្ច**.......... 22
៦.១. ការកត់ត្រាចំណាយចំណូលផលិតកម្ម.......... 22
៦.២. ការប្រើប្រាស់ព័ត៌មានប្រមូលបាន សម្រាប់វិភាគចំណាយចំណូលផលិតកម្ម.......... 24

ឧបសម្ព័ន ១: សន្លឹកគំរូកំណត់ត្រាចំណាយចំណូលផលិតកម្ម
(ស្រង់ពីកំណត់ត្រាកសិកររបស់គម្រោង TSTD) .......... 26
ឧបសម្ព័ន ២: បញ្ជីរាយនាមអ្នកពាក់ព័ន្ធទំនាក់ទំនងសង្វាក់ទីផ្សារស្រូវ.......... 28

**ឯកសារយោង**.......... 29

# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD) ជាគម្រោងជំនួយបច្ចេកទេស ដែលផ្តល់សហ-ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្ត ដោយរដ្ឋាភិបាលហ្វាំងឡង់ មូលនិធិដៃគូអ៊ី-អាស៊ី និងចែករំលែកពុទ្ធិនៃសាធារណរដ្ឋកូរ៉េ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ រាជរដ្ឋាភិបាលកម្ពុជាចូលរួមបដិភាគ មិនមែនជាថវិកា (ធនធានមនុស្ស ការិយាល័យបំពេញការងារ...) សម្រាប់អនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ីជាអ្នកចាត់ចែងប្រតិបត្តិការផ្ទាល់ ជំនួសមុខឱ្យម្ចាស់ជំនួយ ។ គម្រោងបានធ្វើការសាកល្បងបង្ហាញបច្ចេកវិទ្យាកសិកម្ម និង ផ្តល់សេវាព័ត៌មានជនបទ ដើម្បីបង្កើនប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។

គម្រោងបានអនុវត្ត *កម្មវិធីធ្វើបង្ហាញបច្ចេកវិទ្យាផលិតកម្មស្រូវពូជជាក្រុមសម្រាប់លក់* ក្នុងខេត្តទាំងបួន ។ ដោយសហការជាមួយមន្ត្រីកសិកម្មក្នុងខេត្តទាំងបួន គម្រោងបានអនុវត្តកម្មវិធីធ្វើបង្ហាញ និង បណ្តុះបណ្តាលបច្ចេកទេសផលិតកម្មស្រូវពូជ ដោយប្រើវិធីសាស្ត្របង្រៀន ឱ្យធ្វើអនុវត្តជាក់ស្តែង ជាជំហានៗ តាមដំណាក់កាលលូតលាស់ ពេញមួយវដ្តដំណាំ។ សៀវភៅណែនាំបច្ចេកទេសស្តីពី **ផលិតកម្មស្រូវពូជ** នេះ បានរៀបចំឡើងដើម្បីផ្តល់នូវចំណេះដឹង និង ចំណេះធ្វើជាក់ស្តែង ដល់ក្រុម និងគ្រួសារកសិករ ស្តីពីបច្ចេកទេសផលិត និង រៀបចំសំអាតវេចខ្ចប់សម្រាប់លក់។

ខ្លឹមសារក្នុងសៀវភៅណែនាំបច្ចេកទេសនេះ បានរៀបចំឡើង ដោយក្រុមអ្នកបច្ចេកទេស របស់គម្រោងសម្រាប់កសិករ ដោយផ្អែកលើជំហានអនុវត្តជាក់ស្តែង និង បទពិសោធន៍ទទួលបានជោគជ័យ ក្នុងការផលិតស្រូវពូជជាក្រុមសម្រាប់លក់ រយៈពេលពីររដូវ (២០១២ - ២០១៣) កន្លងមក នៅក្នុងខេត្តទាំងបួន ។

ការអនុវត្តកម្មវិធីធ្វើបង្ហាញ និងបណ្តុះបណ្តាល ស្តីពី **ផលិតកម្មស្រូវពូជ** នេះ អាចទទួលបានជោគជ័យដោយមានការគាំទ្រជាប់ជាបន្តពីថ្នាក់ដឹកនាំ និងបុគ្គលិកក្រុមទីប្រឹក្សាគម្រោង ពី លោក **ប្រាក់ ថាវអមិដា** ប្រធានសម្របសម្រួលគម្រោង TSTD និង ជាអគ្គលេខាធិការរង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង លោក **លីវ លាងហ៊ី** ប្រធានក្រុមទីប្រឹក្សាគម្រោង និង ពីមន្ត្រីបច្ចេកទេសនៃមន្ទីរកសិកម្មខេត្តទាំងបួន។

**រៀបរៀងដោយ៖**



| | |
|---|---|
| **លោក ពិត ខុនហ៊ែល** | អ្នកជំនាញផ្នែកក្សេត្រសាស្ត្រ/បន្លែ របស់គម្រោង TSTD |
| ទូរស័ព្ទ: | (855)-12 585 892 |
| អ៊ីម៉ែល: | khonhel@gmail.com |

## ១. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា កំពុងអនុវត្តគោលនយោបាយ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈការបង្កើនការផលិត និងនាំអង្ករចេញ ឱ្យបានយ៉ាងតិច ១លានតោន ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៥ តទៅ។ ឆ្លើយតបចំពោះគោលនយោបាយនេះ គម្រោង TSTD បានអនុវត្តកម្មវិធីធ្វើបង្ហាញស្តីពី *ផលិតកម្មពូជស្រូវជាក្រុមសម្រាប់លក់* ក្នុងខេត្តគោលដៅទាំងបួន ដោយប្រើពូជស្រូវសម្រាប់នាំចេញទាំង ១០។ គោលបំណរបស់កម្មវិធីធ្វើបង្ហាញ នេះ គឺៈ

- បញ្ជ្រាបចំណេះដឹង ឱ្យកសិករចេះដាំដុះស្រូវពូជ ឱ្យមានគុណភាពសុទ្ធល្អ
- បង្ហាញបច្ចេកទេសផលិតស្រូវពូជដែលមានគុណភាពសុទ្ធ និងមានដំណុះល្អ
- ផ្សព្វផ្សាយ និងលក់ស្រូវពូជដែលមានគុណភាពសុទ្ធល្អដល់កសិករនៅក្នុងតំបន់
- បង្កើនមុខរបរ និងប្រភពចំណូលដល់ក្រុមកសិករ
- ចូលរួមចំណែកក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការលក់ពូជ សុទ្ធ ឱ្យកសិករបានប្រើប្រាស់ ។
- ជួយឱ្យកសិករនៅតាមជនបទ អាចរកពូជដែលមានគុណភាពល្អមកដាំដុះ

## ២.ផលិតកម្មគ្រាប់ពូជ

### ២-១. *សម្ភារៈសម្រាប់ការងារផលិតកម្មស្រូវពូជ*

១- ពូជស្រូវ (ចំណាត់ថ្នាក់ ពូជសុទ្ធគ្រឹះ) បរិមាណ ២០គីឡូក្រាម សម្រាប់ដីស្រែ ១ ហិកតា
២- ជីគីមី (កម្រិតប្រើទៅតាមប្រភេទពូជ ប្រភេទដី និង រដូវកាលដាំដុះ)
៣- សំពត់តង់សម្រាប់ហាលស្រូវ
៤- ជញ្ជីងប៉ុង
៥- សំបកបាវ (ដោយមានបោះពុម្ពផ្លាក)
៦- ម៉ាស៊ីនដេរមាត់បាវ
៧- ម៉ាស៊ីនបក់សម្អាតគ្រាប់ស្រូវ
៨- ឧបករណ៍វាស់សំណើមគ្រាប់
៩- ទីតាំងជាឃ្លាំងរក្សាទុកដាក់គ្រាប់ពូជ

### ២-២. *ពូជស្រូវដែលប្រើប្រាស់*

ពូជស្រូវទាំង ១០ពូជ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្សព្វផ្សាយដល់កសិករធ្វើការដាំដុះៈ

| **លរ** | **ឈ្មោះពូជ** | **អាយុកាល** (ថ្ងៃ) | **ទិន្នផល** (តោន / ហាត) |
|---|---|---|---|
| | *ស្រូវស្រាល មិនប្រកាន់រដូវ* | | |
| ១ | អ៊ីរ៉ែ-៦៦ | ១០៥ - ១១៥ | ៤,០- ៦,៥ |
| ២ | ជលសារ | ៩៥ - ១១០ | ៤,០- ៦,០ |
| ៣ | សែនពិដោរ | ១១០ - ១២០ | ៣,៥- ៥,៥ |

| | | | |
|---|---|---|---|
| | ***ស្រូវកណ្ដាលក្រអូបប្រកាន់រដូវ*** | | |
| ៤ | ផ្ការំដួល | ពាក់កណ្ដាល ខែតុលា | ៣,៥- ៥,៥ |
| ៥ | ផ្ការំដេង | ពាក់កណ្ដាល ខែតុលា | ៣,៥- ៥,៨ |
| ៦ | ផ្ការមៀត | ពីថ្ងៃ15 ទៅ 25 ខែតុលា | ៣,៥- ៥,៨ |
| | ***ស្រូវកណ្ដាល-ធ្ងន់ ប្រកាន់រដូវ*** | | |
| ៧ | ផ្កាច័ន្ទសែនស | ចុងខែតុលា - ដើមវិច្ឆិកា | ៣,៥- ៥,០ |
| ៨ | ខា-៤ | ពាក់កណ្ដាល ខែវិច្ឆិកា | ២,៥- ៥,០ |
| ៩ | ខា-៦ | ពាក់កណ្ដាល ខែវិច្ឆិកា | ៣,៥- ៥,០ |
| ១០ | រាំងជ័យ | ពាក់កណ្ដាល ខែវិច្ឆិកា | ៣,៥- ៥,៥ |

## ២-៣- *ការជ្រើសសំរាំងយកគ្រាប់ពេញ និងត្រាំផ្អាប់គ្រាប់ពូជ*

យកគ្រាប់ពូជទៅហាលថ្ងៃ រយៈពេលពី ២ ទៅ ៣ម៉ោងសិន ដើម្បីដាស់ដំណេកគ្រាប់ រួចទុកឱ្យត្រជាក់ ។



ចាក់ទឹក និងដាក់ពងមាន់១ក្នុងធុង ឬ ចានដែក ហើយចាក់អំបិលលាយ រហូតទាល់តែពងមាន់ដែលដាក់ក្នុងទឹកអណ្ដែតឡើង ចាក់គ្រាប់ពូជចូលប្រមាណពាក់កណ្ដាល ហើយកូរឱ្យសព្វ កៀរយកសំដី គ្រាប់ស្មៅ និងគ្រាប់ស្រូវណាដែលអណ្ដែតចេញ ស្រង់យកគ្រាប់ដែលលិចទុកដោយឡែក មុនយកគ្រាប់ទៅផ្អាប់ ត្រូវលាងទឹកឱ្យស្អាតសិន ច្រកគ្រាប់ស្រូវដែលបានសំរាំងហើយចូលក្នុងបាវចងមាត់ ហើយដាក់ត្រាំទឹករយៈពេល ២៤ម៉ោង ទើបស្រង់ដាក់ផ្អាប់ ចំនួន២៤ម៉ោងទៀត ដោយយកចំបើង ឬ សំបកបាវសើម គ្របពីលើដើម្បីបង្កើនកំដៅ ។





## *២-៤- ការរៀបចំថ្នាលសំណាប និងការសាប*

- ត្រូវរៀបចំថ្នាលសំណាបដោយបំផុសដីឱ្យបានម៉ដ្ឋ ហាលថ្ងៃឱ្យបាន ពី៧ ទៅ ១០ថ្ងៃ សំអាតស្មៅ និង ពង្រាបដីឱ្យ បានរាបស្មើ ។
- ប្រើជីធម្មជាតិ (ជីកំប៉ុស្ត) ដែលពុកផុយល្អ ក្នុងបរិមាណប្រហែល ២០០គីឡូក្រាម (គ.ក្រ) ឬ ប្រហែល ១ រទេះគោ សម្រាប់ផ្ទៃដីថ្នាលសាបទំហំ ១០០ ម៉ែត្រការ៉េ (ម$^{២}$)។ ជីធម្មជាតិនេះ ត្រូវប្រើជាជីទ្រាប់បាតនៅពេលរៀបចំដី ដោយពង្រាយវា ឱ្យបានសព្វពេញថ្នាល ។
- រៀបចំជាថ្នាលសំណាបគោក ដែលមានទីតាំងនៅក្បែរប្រភពទឹកមានពន្លឺថ្ងៃគ្រប់គ្រាន់ និង ងាយស្រួល ក្នុងការការពារ។ ថ្នាលអាចលើកជារង ដែលមានទទឹង ពី ១,២ ទៅ ១,៥ ម៉ែត្រ និង បណ្តោយ អាស្រ័យ លើស្ថានភាពដីជាក់ស្តែង ។
- ដង់ស៊ីតេគ្រាប់ពូជសម្រាប់សាប គឺប្រមាណ ០,១ គ.ក្រ (១ ខាំ) សម្រាប់ផ្ទៃថ្នាលទំហំ ១ ម$^{២}$
- សម្រាប់ស្ទូងលើដី ១ ហិកតា ត្រូវការថ្នាលសំណាបទំហំ ពី ១៥០ ទៅ ២០០ ម$^{២}$ និងត្រូវការ គ្រាប់ពូជសុទ្ធ គុណភាពល្អ ចំនួនពី ១៥ ទៅ ២០ គីឡូក្រាម ។






## *២-៥. ការដកសំណាប*

-ស្រូវស្រាល ដកស្ទូង ពេលសំណាបអាយុ ពី ១៧ ទៅ ២០ថ្ងៃ

-ស្រូវកណ្តាល ដកស្ទូង ពេលសំណាបអាយុ ពី ២៥ ទៅ ៣០ថ្ងៃ
-ស្រូវធ្ងន់ ដកស្ទូង ពេលសំណាបអាយុ ពី ៣០ ទៅ ៣៥ថ្ងៃ









## ២-៦- ការរៀបចំដីស្រែ

ការភ្ជួររាស់ដីស្រែ អាចប្រើប្រាស់ដោយត្រាក់ទ័រ គោយន្ត ឬ កម្លាំងគោ ក្របី ។ ការភ្ជួរដីលើកទី១ ត្រូវចាប់ផ្តើមនៅក្រោយពេលច្រូតកាត់ភ្លាមៗ ព្រោះដីនៅមានសំណើម សមស្រប ។ ពេលវេលានៃការភ្ជួរលើកទី ២ អាចធ្វើមុនពេលស្ទូង រយៈពេលពី ១ ទៅ ២ សប្តាហ៍ ដើម្បីឱ្យស្មៅរលួយ។ ជម្រៅនៃការភ្ជួររាស់ គឺប្រែប្រួលទៅតាមប្រភេទដី ដូចជាប្រភេទដីល្បាយខ្សាច់ ជម្រៅពី ៨ ទៅ ១២សង់ទីម៉ែត្រ (ស.ម) ហើយ ដីល្បាយឥដ្ឋ ជម្រៅ ពី ១៥ ទៅ ២៥ សង់ទីម៉ែត្រ។



## ២-៧. ការស្ទូង

### ២-៧-១- ការរៀបចំខ្សែខ្នាតស្ទូង

រៀបចំខ្សែលួស សម្រាប់ធ្វើជាខ្សែខ្នាតស្ទូង ដោយក្ងួចជាខ្នាតចន្លោះ ២០ ស.ម (២តឹក) ពីគ្នា ។



## ២-៧-២. *ការស្ទូងជាជួរ*

ស្ទូងជាជួរ ដោយប្រើខ្សែខ្នាតដែលមានចន្លោះគុម្ព ២០ស.មx២០ស.ម  ស្ទូង ពី១ ទៅ ២ដើម ក្នុង ១ គុម្ព ក្នុងករណីសំណាបថ្លោសល្អ និងមានអាយុកាលខ្ចីការស្ទូងសំណាបថ្លោស និងមានសុខភាពល្អ ធ្វើឱ្យសន្ទូងឆាប់លូតលាស់ និងបែកគុម្ពបានល្អ ប្រជែងឈ្នះស្មៅ ធន់ទ្រាំ នឹងការបំផ្លាញរបស់សត្វល្អិត និង ជម្ងឺផ្សេងៗ ជាពិសេសធ្វើឱ្យយើងងាយស្រួលស្ទូង ១ដើម ក្នុង១គុម្ព តែម្តង។














ចន្លោះគុម្ព ២០ស.ម x ២០ស.ម (២តឹក)

## ២-៨. ការប្រើប្រាស់ជី




### ២-៨-១. ប្រភេទជី និង ការប្រើប្រាស់ជី

កម្រិតណែនាំការប្រើប្រាស់ជីទៅតាមក្រុមដី សម្រាប់ផលិតកម្មដំណាំស្រូវ

| លរ | ក្រុមដី | បទដ្ឋានដី Noo,Poo,Koo | ចំនួនជី (គ.ក្រ - kg) CARDI | | ចំនួនជី (គ.ក្រ - kg) នាយកដ្ឋានផ្សព្វផ្សាយ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | កំពង់សៀម | 50-00-00 | -អ៊ុយរ៉េ | : 109Kg | -អ៊ុយរ៉េ | : 110 kg | ពូជទំនើប ឬ ប្រពៃណី |
| | | 98-18-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 39 kg<br>: 197 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 40 kg<br>: 200 kg | ពូជទំនើប ឬ ប្រពៃណី |
| ២ | កៀនស្វាយ ឬ ក្រគរ | 120-35-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 54 kg<br>: 239 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 50 kg<br>: 125 kg | ពូជទំនើប ឬ ប្រពៃណី |
| | | 66-23-00 | | | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 50 kg<br>: 124 kg | ពូជទំនើប ឬ ប្រពៃណី |
| ៣ | ប្រទះឡាង | 50-23-30 | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 50 kg<br>: 50 kg<br>: 89 kg | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 50 kg<br>: 50 kg<br>: 90 kg | ពូជទំនើប ឬ ប្រពៃណី (ករណីមានទឹកគ្រប់គ្រាន់) |
| | | 33-23-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 50 kg<br>: 52 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 50 kg<br>: 50 kg | ពូជទំនើប ឬ ប្រពៃណី (ករណីមានទឹកគ្រប់គ្រាន់) |
| ៤ | ទួលសំរោង | 98-23-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 76 kg<br>: 184 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 75 kg<br>: 184 kg | ពូជទំនើប |
| | | 61-24-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 52 kg<br>: 113 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 50kg<br>: 113kg | ពូជប្រពៃណី |
| ៥ | ព្រៃខ្មែរ | 28-10-40 | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 21 kg<br>: 67 kg<br>: 52 kg | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 25 kg<br>: 67 kg<br>: 50 kg | ពូជទំនើប ឬ ប្រពៃណី |
| | | 20-08-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 17 kg<br>: 37 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 17 kg<br>: 38 kg | ពូជទំនើប ឬ ប្រពៃណី |
| ៦ | បាកាន ឬ អូររាំង | 75-30-30 | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 65 kg<br>: 50 kg<br>: 137 kg | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 65 kg<br>: 50 kg<br>: 140 kg | ពូជទំនើប |
| | | 75-30-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 65 kg<br>: 17 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 65 kg<br>: 140 kg | ពូជទំនើប |
| | | 60-17-20 | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 37 kg<br>: 34 kg<br>: 117 kg | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 38 kg<br>: 34 kg<br>: 117 kg | ពូជប្រពៃណី |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 60-17-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 37 kg<br>: 117 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 38 kg<br>: 117 kg | ពូជប្រពៃណី |
| ៧ | ក្បាលពោធិ៍ | 80-00-00 | -អ៊ុយរ៉េ | : 175 kg | -អ៊ុយរ៉េ | : 175 kg | ពូជទំនើប ឬ ប្រពៃណី |
| ៨ | គោកត្រប់ | 73-35-30 | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 76 kg<br>: 50 kg<br>: 122 kg | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 75 kg<br>: 50 kg<br>: 125 kg | ពូជទំនើប |
| | | 65-30-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 65 kg<br>: 115 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 65 kg<br>: 115 kg | ពូជទំនើប |
| | | 58-30-00 | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 67 kg<br>: 50 kg<br>: 100 kg | -ដេអាប៉េ<br>-កាសេអ៊ិល<br>-អ៊ុយរ៉េ | : 67 kg<br>: 50 kg<br>: 100 kg | ពូជប្រពៃណី |
| | | 49-23-00 | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 50 kg<br>: 87 kg | -ដេអាប៉េ<br>-អ៊ុយរ៉េ | : 50 kg<br>: 88 kg | ពូជប្រពៃណី |

### ២-៨-២. ជីទ្រាប់បាត

- បាចក្រោយពេលរាស់ និងកៀរដីស្រែបានស្អាតហើយ ឬក៏ បាចមុនពេលស្ទូង
- បរិមាណសរុបជីផូស្វ័រ (P) និង ជីប៉ូតាស្យូម (K) ដែលត្រូវប្រើបាចទាំងអស់ (១០០%)
- បរិមាណជីអាសូត (N) ត្រូវបាចចំនួន៥០ ភាគរយ (៥០%) ចំណែក បរិមាណ ៥០% (ពាក់កណ្ដាល) ទៀតទុកប្រើជាជីបំប៉ន ។



### ២-៨-៣. ជីបំប៉ន

- សម្រាប់ប្រភេទស្រូវស្រាល បាចតែ១ដងទៀត ក្រោយពេលស្ទូងបានចំនួន៣០ថ្ងៃ គឺ បាចបរិមាណជីអាសូត ដែលនៅសល់ចំនួន ៥០% (ពាក់កណ្ដាល) ទៀត។

- សម្រាប់ប្រភេទស្រូវកណ្តាល និងស្រូវធ្ងន់ បាច២លើកទៀត គឺ បាចក្រោយពេលស្ទូងបាន ចំនួន៣០ថ្ងៃ ជីអាសូត ចំនួន ២៥ ភាគរយ (១ ភាគ ៤) និង បាចពេលស្រូវចេញកក្ឋរ បរិមាណជីអាសូតចំនួន ២៥% ទៀត ។



## ២-៩- *ការថែទាំសន្ទូង និងការគ្រប់គ្រងទឹក*

ដើម្បីឱ្យការគ្រប់គ្រងទឹកបានត្រឹមត្រូវ ដីស្រែត្រូវរាបស្មើ និងមានភ្លឺមាំទាំ។ ទឹកក្នុងស្រែ មានជម្រៅប្រហាក់ប្រហែលគ្នានៅក្នុងស្រែទាំងមូល និងធ្វើឱ្យដំណាំដុះលូតលាស់ស្មើគ្នា ផ្តល់ទិន្នផលខ្ពស់ ហើយស្រូវក៏មានសំណើមប្រហាក់ប្រហែលគ្នា។ ការគ្រប់គ្រងទឹកបានល្អ ក៏ជួយធ្វើឱ្យមានស្មៅចង្រៃតិច ដែលមិនត្រឹមតែធ្វើឱ្យបានទិន្នផលខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យស្រូវស្អាត មិនសូវមានសម្រាម (រួមមាន កំទេចកំទី សម្រាម សំដី គ្រាប់ស្កក មិនពេញ...) ផងដែរ។

## ២-១០- *ការចុះកាត់ពូជលាយ*

ពូជដែលលាយ គឺជាពូជស្រូវទាំងឡាយណាដែលយើងមិនត្រូវការ ។ រាល់ដើមស្រូវទាំងឡាយណាដែលមិនមានលក្ខណៈដូចពូជដែលផលិត ត្រូវតែដកចោលទាំងគុម្ពជាបន្ទាន់ ។ ដើម្បីបែងចែកដើមស្រូវដែលលាយ យើងត្រូវមើលលក្ខណៈ ដូចខាងក្រោម ៖

- **ការកាត់ពូជលាយលើកទី១៖** ចាប់ពីដំណាក់កាលបែកគុម្ព រហូតដល់លូតកំពស់ដើម ពិនិត្យមើលលក្ខណៈបែកគុម្ព ព៌ណដើម ស្លឹក និងកំពស់ ដើមដែលសង្ស័យ ត្រូវដកចោលទាំងឬស ។

- **ការកាត់ពូជលាយលើកទី២៖** ចាប់ពីដំណាក់កាល ចេញផ្កាដំបូង រហូតដល់ដំណាក់កាលដាក់ទឹកដោះ *(ពូជលាយជាច្រើន អាចកត់សំគាល់ឃើញយ៉ាងច្បាស់នៅពេលស្រូវចេញផ្កា)* ។ គុម្ពណាដែលចេញផ្កាមុន ឬក្រោយគេមួយសប្តាហ៍ត្រូវកាត់ចោល ។ ក្រៅពីនេះពិនិត្យទៅលើកំពស់ដើមខ្ពស់ ឬទាបព័ណដើម ព័ណស្លឹក ទំហំស្លឹក ប្រវែងស្លឹក លក្ខណៈរបស់ស្លឹកទង់ជ័យ លក្ខណៈរបស់កួរ  ព័ណរបស់គ្រាប់ស្រូវ ប្រវែងគ្រាប់ វែង ឬខ្លី ព័ណចុងគ្រាប់ គ្រាប់មានកន្ទុយ ឬ គ្មាន។

- **ការកាត់ពូជលាយលើកទី៣៖** ជាទូទៅធ្វើនៅរយៈពេល ២សប្តាហ៍មុនច្រូត  ធ្វើការសង្កេត និងកត់សម្គាល់ លើលក្ខណៈរបស់កួរ គ្រាប់ តូច ធំ ប្រវែងកួរ វែង ឬ ខ្លី និងលក្ខណៈផ្សេងៗទៀត ដូចនៅដំណាក់កាលទី១ និង ទី២ ដែរ ។



### *២-១១. ការកំចាត់ស្មៅចង្រៃ*

ដើម្បីគ្រប់គ្រងស្មៅចង្រៃ ប្រកបដោយប្រសិទ្ធភាព កសិករត្រូវអនុវត្តការភ្ជួរដាស់ដី នៅពេលមានសំណើមគ្រប់គ្រាន់ ត្រូវសម្អាតគ្រាប់ពូជស្រូវ ឱ្យស្អាត កុំឱ្យមានគ្រាប់ស្មៅ ។ រៀបចំដីស្រែឱ្យបានស្អាត និង រាបស្មើល្អ ធ្វើស្មៅ បំផុសដី យ៉ាងតិច ២ដង ដោយដៃ ឬ ប្រើឧបករណ៍ធ្វើស្មៅ ឬ ប្រើថ្នាំកំចាត់ស្មៅ។



### *២-១២- ការកំចាត់សត្វកណ្តុរ*

- ដាក់បំពង់ឬស្សី ឬ ទុយយោក្បែរភ្លឺស្រែ ដើម្បីប្រមូលកណ្តុរ
- ប្រើអង្គប់ចាប់កណ្តុរ
- ប្រើកៅស៊ូប្លាស្ទិក ធ្វើជារបាំងជុំវិញស្រែ
- ដាក់នុយលាយជាមួយថ្នាំបំពុលកណ្តុរ (ប្រើថ្នាំ ហ្វូសស្វៀដឹស្សាំង ឬ វ៉ាហ្វារីន លាយជាមួយស្រូវ ពោត អង្ករ ក្តាម ឬ លៀស ហើយដាក់តាមភ្លឺស្រែ ក្នុងស្រែ តាមគន្លងផ្លូវកណ្តុរដើរ មាត់រន្ធ) ។




### *២-១៣- ការប្រមូលផល*

ដើម្បីចៀសវាងការបាត់បង់ទិន្នផល ដែលបណ្តាលមកពីការដួលដើម បាក់ក្ហួរ ជ្រុះគ្រាប់ ឬ ការបំផ្លាញដោយសត្វចាប និងកណ្តុរ ត្រូវធ្វើការច្រូតកាត់ឱ្យទាន់ពេលវេលា ។ វាយតំលៃទៅលើភាពទុំរបស់ស្រូវ ឱ្យបានត្រឹមត្រូវ ហើយការប្រមូលផលស្រូវ គួរធ្វើនៅពេលស្រូវទុំបានពី៨០ ទៅ ៨៥% ។ ការច្រូតកាត់ បានទាន់ពេលវេលា ធ្វើឱ្យគ្រាប់ពូជមានគុណភាពដំណុះល្អ និងសំណាបមានសុខភាពល្អ ។



## ២-១៣-១ *ប្រមូលផល ច្រូតកាត់ បោកបែនដោយដៃ*

ការច្រូត និងបោកបែនដោយដៃ គ្រាប់ពូជមានដំណុះល្អ ដោយសារវាពុំទទួលរងនូវការកកិត និង ប៉ះទង្គិចខ្លាំងធ្វើឱ្យមានការបាក់បែកគ្រាប់ និង កំពីងពន្លក (របស់គ្រាប់ស្រូវ) ។



## ២-១៣-២. *ប្រមូលផល ច្រូតកាត់ បោកបែនដោយគ្រឿងម៉ាស៊ីន*

ការប្រមូលផលច្រូតកាត់ដោយគ្រឿងម៉ាស៊ីនលឿនទាន់ពេលវេលា តែធ្វើឱ្យមានការបាត់បង់ ទិន្នផលដោយការជ្រុះគ្រាប់ ខ្ចាត់ខ្ចាយ ។ ហើយការបោកបែនដោយគ្រឿងម៉ាស៊ីន ធ្វើឱ្យគ្រាប់ទទួលរង នូវការកកិត និងបោកទង្គិចខ្លាំងដែលធ្វើឱ្យមានការបាក់បែកគ្រាប់ និងកំពីងពន្លកដែលជាផលប៉ះពាល់ ទៅលើដំណុះគ្រាប់ និង ជាគុណវិបត្តិ ដ៏ខ្លាំងទៅលើភាពសុទ្ធនៃគ្រាប់ពូជ ដោយការបោកដោយម៉ាស៊ីន បណ្តាលឱ្យមានការលាយឡំពូជច្រើន ។ ប្រសិនបើការច្រូតកាត់ត្រូវប្រើប្រាស់ដោយ *ម៉ាស៊ីនកុំបៃ* ដែល

ច្រូតចេញជាគ្រាប់ គ្រាប់ស្រូវដែលត្រេងចេញពីម៉ាស៊ីន ចំនួនពី២ ទៅ ៣បាវដំបូង ត្រូវដកចេញពីបរិមាណស្រូវទុកធ្វើជាគ្រាប់ពូជ។ បើបោកបែន ដោយប្រើ *ម៉ាស៊ីនបោកធម្មតា* ត្រូវបោស និងលាងសម្អាតម៉ាស៊ីនជាមុន ដោយប្រើកម្លាំងខ្យល់បាញ់សម្អាតគ្រាប់ស្រូវ ដែលនៅសេសសល់ ជាប់នឹងម៉ាស៊ីនឱ្យបានស្អាតជាមុន គ្រាប់ស្រូវដែលត្រេងចេញពីម៉ាស៊ីន ចំនួនពី១ ទៅ ២បាវដំបូង ត្រូវដកចេញពីបរិមាណស្រូវ ទុកធ្វើជាគ្រាប់ពូជ ។



## ៣-កិច្ចប្រតិបត្តិការខារបច្ចេកទេសក្រោយពេលប្រមូលផល

### *៣-១- ការហាលសំងួត*

គ្រាប់ស្រូវដែលទើបច្រូតកាត់ និងបោកបែនរួច មានសំណើមពី ១៨ ទៅ ២៥ភាគរយ (%) ជាគ្រាប់ស្រូវ ដែលនៅសើមខ្លាំង ដូច្នេះពុំត្រូវទុកផ្ទាប់យូរបានឡើយ វាធ្វើឱ្យស្រូវពុកផុយដោយសារប្រតិកម្មចំហេះ បង្ករជាផ្សិត និង មានសត្វល្អិតចង្រៃបំផ្លាញច្រើនក្នុងជង្រុក និងបាវ ។ ត្រូវធ្វើការហាលសម្ងួតដោយកំដៅថ្ងៃ ដោយប្រើសំពត់តង់ក្រាល ហើយចាក់ហាល រាយស្មើង មិនត្រូវចាក់គ្រាប់ពូជហាលផ្ទាល់នឹងកម្រាលស៊ីម៉ង់ត៍(លាន) ទេ ពីព្រោះកម្រាលស៊ីម៉ង់ត៍ ក្តៅខ្លាំងបណ្តាលឱ្យងាប់ដំណុះគ្រាប់ ។

ដើម្បីសម្ងួតគ្រាប់ស្រូវឱ្យបានសំណើម ១៤% ត្រូវហាលដោយកំដៅថ្ងៃឱ្យបាន ២ថ្ងៃយ៉ាងតិច (ករណីមានពន្លឺថ្ងៃគ្រប់គ្រាន់) ។









### ៣-២- ការបក់សំអាតគ្រាប់

គ្រាប់ស្រូវដែលស្ងួតហើយត្រូវយកមកបក់សម្អាត យកសំដី និងកំទេចកំទីសំរាមចេញ  ដោយប្រើ ម៉ាស៊ីនបក់ ប្រើដោយអាគុយ ឬ ចរន្តអគ្គិសនី ។



### ៣-៣- ការច្រកខ្ចប់

ក្រោយពីគ្រាប់ពូជបានសម្អាតស្រេចបាច់ហើយ គ្រាប់ពូជអាចច្រកចូលក្នុងបាវ ហើយដេរភ្ជិតមាត់ បាវ ដោយម៉ាស៊ីនដេរ ទើបយកទៅរក្សាទុកដាក់ ក្នុងឃ្លាំង ឬ ទីកន្លែងស្តុក ដែលមានសុវត្ថិភាព ។



### ៣-៤- ការទុកដាក់ ថែទាំគ្រាប់ពូជ



ដើម្បីទុកដាក់គ្រាប់ពូជឱ្យមានសុវត្ថិភាព គ្រាប់ពូជត្រូវមានអត្រាសំណើមទាបជាង ១៣-១៤% ហើយការទុកដាក់ក្នុងបរិក្ខារ បិទជិត អាចរក្សាអត្រាដំណុះខ្ពស់ជាង។ ការទុកដាក់បានល្អ នឹងធ្វើឱ្យថយចុះនូវការបំផ្លាញពី សត្វល្អិត សត្វកណ្តុរ និងជម្ងឺផ្សិត។ជង្រុក ឬកន្លែងស្តុកស្រូវពូជត្រូវតែជាទីកន្លែងដែលស្ងួត មានខ្យល់ចេញចូលល្អ មានដំបូល និងជញ្ជាំងជិតល្អ មិនជ្រាបទឹក និងគ្មានកណ្តុរបំផ្លាញ ។ បាវគ្រាប់ពូជ ត្រូវតំរៀបជាជួរ ជាឡូតិ៍ ទៅតាមពូជ លើកំណល់ឈើ ផុតពីកម្រាលឥដ្ឋ ។





### ៣-៥- វិធីយកសំណាកគ្រាប់ពូជ

- **ករណីគ្រាប់ពូជនៅក្នុងគំនរ ឬ ជង្រុកចាក់ជារ ៖**

  ចាក់ឆាំ (ដែកបំពង់ចាកយកសំណាកគ្រាប់ស្រូវ) ចូលក្នុងគំនរគ្រាប់ពូជ ឬ ជង្រុក នៅចំណុចខុសៗគ្នា ជាច្រើនកន្លែងហើយយកមក ប្របល់ចូលគ្នាឱ្យសព្វ ។

- **ករណីគ្រាប់ពូជនៅក្នុងបាវ៖**

  ចាក់ឆាំចូលក្នុងបាវ នៅកន្លែង និងកំពស់ផ្សេងៗគ្នា ។ ចំនួនបាវយកសំណាក ត្រូវស្មើនឹងឬសការ៉េ នៃចំនួនបាវសរុប ។  ឧទាហរណ៍ ៖

  - បើចំនួនបាវមាន ៤ គួរយកសំណាកពី ២ បាវ
  - បើចំនួនបាវមាន ៩ គួរយកសំណាកពី ៣ បាវ
  - បើចំនួនបាវមាន ១៦ គួរយកសំណាកពី ៤ បាវ
  - បើចំនួនបាវមាន ១០០ គួរយកសំណាកពី ១០បាវ ...។ល។

បរិមាណសំណាកគ្រាប់ពូជសរុប ដែលទទួលបានពីការឆាំមក ត្រូវលាយប្របល់ចូលគ្នាឱ្យសព្វ ហើយញែកចែកជា ២ចំណែក ឬ ថ្លឹងចែកជា២ចំណែក រួចយកតែ ១ចំណែក ហើយចែកជា២ចំណែកបន្តទៀត រហូតដល់១ ចំណែក មានបរិមាណតែ ពី ៤០ ទៅ ៥០ក្រាម ដែលជាបរិមាណសំណាកចុងក្រោយ សម្រាប់យកមកធ្វើតេស្តដំណុះគ្រាប់ និង ធ្វើតេស្តវាស់សំណើមគ្រាប់ ។




### ៣-៦- *ការធ្វើតេស្តដំណុះ*

ដើម្បីធ្វើតេស្តដំណុះគ្រាប់ពូជស្រូវ យើងត្រូវមាន ៖

១- សំណាកគ្រាប់ពូជ ដែលទទួលបានពីការធ្វើសំណាក(យកចេញពីបាវ ឬ កន្លែងស្តុក)

២- កូនកញ្ច្រែងជ័រ

២- ក្រដាស់ជក់ទឹក

៤- បំពង់បាញ់ទឹក

៥- ដង្កៀបចាប់គ្រាប់ស្រូវ






ដាក់ក្រដាស់ជក់ទឹក ពី ២ ទៅ ៣ ស្រទាប់ក្នុងកូនកញ្ច្រែងជ័រ ហើយបាញ់ទឹកអោយជោក ប្រើដង្កៀប ចាប់រាប់គ្រាប់ស្រូវចំនួន១០០គ្រាប់ដោយចៃដន្យ ដាក់ជា១០ជួរ រួចបាញ់ទឹកស្រោចឱ្យជោក ហើយ ច្រកគ្របដោយថង់ប្លាស្ទិច ក្នុង១ពូជ ត្រូវធ្វើជា ២សារ (គឺថា ធ្វើដូចគ្នា ម្តងទៀត) ដើម្បីបន្ថយកម្រិតលំអៀង។ ទុកកូនកញ្ច្រែងជ័រ ក្នុងកន្លែងមានសុវត្ថិភាព មានពន្លឺមធ្យម ពុំមានសត្វកណ្តុរ ។ នៅថ្ងៃទី៣ បន្ទាប់ពីបណ្តុះ ចាប់រាប់ដំណុះគ្រាប់លើកទី១ និង ថ្ងៃទី៧ រាប់លើកចុងក្រោយ ដើម្បីរកអត្រាដំណុះ ។

### *៣-៧- របៀបវាស់រកអត្រាសំណើមគ្រាប់ ៖*

- ត្រូវរើសសម្រាមផ្សេងៗចេញពីគ្រាប់ស្រូវ
- បើវាស់គ្រាប់ស្រូវកំពុងសម្ងួត ត្រូវទុកឱ្យវាត្រជាក់សិន
- ត្រូវវាស់ ៣ដង ទើបគិតយកតំលៃមធ្យម

*-<u>របៀបវាស់</u>*

- ដាក់គ្រាប់ស្រូវចូលក្នុងចានសំណាក ឱ្យពេញស្មើ ស៊កចានវាស់ចូលថតវា
- មួលដៃកៀបសង្កត់បំបែកគ្រាប់ស្រូវ (ត្រឹមមួយតឹងដៃ)
- ចុចប៊ូតុងព៌ណក្រហម ដើម្បីវាស់ ( រង់ចាំបន្តិច លទ្ធផលនឹងបង្ហាញលើ កញ្ចក់អេក្រង់ លេខ 1 នៅផ្នែកខាងឆ្វេងប្រាប់ថាជាសំណាកទី១ លេខខាងស្តាំ 12.3 ជាលទ្ធផល សំណើមគ្រាប់ 12.3%) ។
- មួលដៃកៀបបន្ធូរវិញ ដកយកចានសំណាកចេញ ចាក់សំណាកចាស់ចោល ដោយ ប្រើច្រាស់សម្អាត ដាក់គ្រាប់ស្រូវថ្មីចូលចាន ជាសំណាកទី២ ហើយអនុវត្តជាបន្តដូចគ្នា រហូតដល់ទទួលលទ្ធផលសំណាកទី៣ ទើបបន្តចុចលើប៊ូតុងព៌ណក្រហមដើម្បីទទួល បានតួលេខតំលៃមធ្យម ពីសំណាកទាំង៣ ។






*៣-៨- ការដាក់ថ្នាំសម្លាប់ល្អិតដែលស៊ីបំផ្លាញគ្រាប់ពូជនៅក្នុងបាវ*

ករណីមានសត្វល្អិតបំផ្លាញគ្រាប់ពូជនៅក្នុងបាវ ក្នុងពេលរក្សាទុកក្នុងឃ្លាំង ត្រូវដាក់ថ្នាំសម្លាប់ជាបន្ទាន់ ដោយប្រើសំពត់តង់ ឬផ្ទាំងកៅស៊ូដែលមានទំហំធំៗ គ្របពីលើគំនរបាវស្រូវអោយជិតដល់ផ្ទៃកម្រាល និងប្រើថង់ក្រណាត់ច្រកដីខ្សាច់ សង្កត់ជើងអោយជិតជុំវិញ ។ ប្រើគ្រាប់ថ្នាំហ្វូសហ្វីន (Phosphine) ដាក់លើបន្ទះក្រដាស់ ហើយស៊កតាមចន្លោះជួរបាវ ក្នុងបរិមាណ ២-៣ គ្រាប់ សម្រាប់ចំណុះគ្រាប់ស្រូវ ១ តោន ឬ អាចប្រើថ្នាំ សែលហ្វូស (Celphose) (១ កំប៉ុងមាន ១៦ទីប និង ក្នុង១ទីបមាន ២០គ្រាប់ថ្នាំ ។ កម្រិតប្រើ ១.៥គ្រាប់ ក្នុង ១ ម៉ែត្រគូបនៃទីតាំងគំនរបាវស្រូវហើយទុកក្នុងរយៈពេល ១ អាទិត្យ ទើបបើកសំពត់តង់ ឬ ផ្ទាំងកៅស៊ូចំហរចោលពីគំនរបាវ រយៈពេល ពី២ ទៅ ៣ថ្ងៃ ដើម្បីឱ្យអស់ឥទ្ធិពលថ្នាំ ទើបអាចយកមកប្រើប្រាស់បាន ។



## ៤-គុណភាពស្រូវពូជ

ហេតុអ្វីបានជាត្រូវធ្វើឱ្យស្រូវពូជមានគុណភាពល្អ?

-មានដំណុះល្អ
-មានភាពសុទ្ធល្អ
-ដុះលូតលាស់ស្មើគ្នា
-ទុកដាក់បានយូរ
-ផ្តល់ទិន្នផលខ្ពស់
-ងាយលក់ លក់បានថ្លៃ

*៤-១- លក្ខណៈគុណភាពស្រូវពូជ:*

១-សំណើមគ្រាប់
២- ភាពស្អាត
៣- ភាពសុទ្ធ
៤- ភាពប្រេះស្រាំ
៥- ភាពទុំមិនពេញទឹក
៦- គ្រាប់រងការបំផ្លាញដោយជម្ងឺ និងសត្វល្អិត

*៤-១-១-សំណើមគ្រាប់*

*ស្រូវសើមពេកធ្វើឱ្យ:*

ឡើងកម្តៅ ឆាប់ដុះផ្សិត ឬ ពុក សត្វល្អិតងាយបំផ្លាញ

*ស្រូវស្ងួតពេកធ្វើឱ្យ:*

ស្រូវស្រូបសំណើមវិញ ពេលទុកដាក់



*៤-១-២- ស្រូវពូជស្អាតគឺ:* ស្រូវគ្មានសំដី ចំបើង គ្រួស ដី គ្រាប់ស្មៅ នៅលាយឡំ ។ល។

**ស្រូវពូជមិនស្អាតធ្វើឱ្យ:** កើតមានសត្វល្អិត ឆាប់ធ្លាក់ដំណុះ ...។ល។



*៤-១-៣- ស្រូវពូជសុទ្ធគឺ:* ជាពូជតែមួយ មានព៌ណ និងទម្រង់ដូចៗគ្នា និងទំហំគ្រាប់ប៉ុនៗគ្នា ។

**ស្រូវពូជសុទ្ធធ្វើឱ្យ:** ដំណាំដុះលូតលាស់ស្មើគ្នា ទទួលបានទិន្នផលខ្ពស់ ។





*៤-១-៤- គ្រាប់ប្រេះ ឬ ស្រាំ:*

**បណ្តាលមកពី:** ច្រូតមិនទាន់ពេល (ស្រូវស្ងួតហើយ សើមវិញដោយសន្សើម ឬទឹកភ្លៀង) បោកបែនមិនសមស្រប (ស្រូវស្ងួតពេក ឬបោកខ្លាំងពេក ហាលមិនត្រឹមត្រូវ (ក្របានហាល ថ្ងៃក្តៅពេក ហាលមិនសព្វ និងមិនស្ងួតគ្រប់គ្រាន់ ) និង ស្រូវស្ងួត ហើយសើមវិញ (ទទឹក) ។



*៤-១-៥- គ្រាប់ស្រូវនៅស្ទើ:* បណ្តាលមកពីស្រូវមិនទាន់ទុំល្អ និងពូជមិនសុទ្ធ ។



*៤-១-៦-គ្រាប់រងការបំផ្លាញដោយជម្ងឺ និងសត្វល្អិត:*

**បណ្តាលមកពី:** ផ្ទាប់ស្រូវយូរ ក្រហាល ទុកដាក់ស្រូវនៅសើម មានសត្វល្អិត និងជម្ងឺផ្សិតបំផ្លាញ ។

## ៤-២- កម្រិតស្តង់ដាគុណភាពគ្រាប់ពូជ

គុណភាពគ្រាប់ពូជ មានសារៈសំខាន់ណាស់ ក្នុងការកំណត់ទិន្នផល នៅក្នុងផលិតកម្មដំណាំស្រូវ និង ដំណាំផ្សេងៗទៀតទាំងអស់ ។ ដូច្នេះដើម្បីទទួលបានទិន្នផលខ្ពស់ ការប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពជាប្រការចាំបាច់បំផុត ។ គុណភាពគ្រាប់ពូជ ត្រូវកំណត់ដោយកត្តាមួយចំនួនដូចជា ភាពសុទ្ធនៃគ្រាប់ពូជ ការលាយនៃគ្រាប់ពូជមកពីពូជដទៃ ពីដំណាំដទៃទៀត ឬ ពីគ្រាប់ស្មៅ អាត្រាដុះ និង សំណើម ។ ខាងក្រោមនេះជាកម្រិតស្តង់ដាគុណភាពគ្រាប់ពូជ ដែលទទួលស្គាល់កម្រិតក្នុងប្រទេស ។

**កម្រិតស្តង់ដាគុណភាពគ្រាប់ពូជ ដែលទទួលស្គាល់កម្រិត ក្នុងប្រទេសៈ**

| **បរិយាយ** | **គ្រាប់ពូជសុទ្ធអនុញ្ញាត** | **គ្រាប់ពូជសុទ្ធល្អ** |
|---|---|---|
| -ភាពសុទ្ធ (អប្បរិមា) | ៩៨% | ៩៥% |
| -កំទេចកំទីសម្រាម (អតិបរិមា) ក្នុង ១គ.ក្រ ( / គ.ក្រ) | ២% | ៥% |
| -ចំនួនគ្រាប់ស្មៅ (អតិបរិមា) គ្រាប់ ក្នុង ១គ.ក្រ | ២០ | ៣០ |
| -ចំនួនគ្រាប់ដំណាំផ្សេងៗ (អតិបរិមា)គ្រាប់ / គ.ក្រ | ២០ | ៣០ |
| -ពូជផ្សេងៗទៀត (អតិបរិមា) គ្រាប់ / គ.ក្រ | ២០ | ២៥ |
| -ប្រភេទផ្សេងៗទៀត (អតិបរិមា) គ្រាប់ / គ.ក្រ | ០ | ៥ |
| -អត្រាដំណុះ (អប្បរិមា) | ៨៥% | ៨០ |
| -អត្រាសំណើម (អតិបរិមា) | ១៣% | ១៤% |

# ៥. ការផ្សព្វផ្សាយលទ្ធផលធ្វើបង្ហាញ ផលិតកម្មស្រូវពូជ

ក្រោយពីការបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មស្រូវពូជ តាមទីតាំងទីតាំងបង្ហាញនានា ក្នុងខេត្តទាំង៤ខេត្ត អស់រយៈពេលជាង ១ ឆ្នាំមក គម្រោង បានពិធីបូកសរុបផ្សព្វផ្សាយលទ្ធផលស្តីពីការធ្វើបង្ហាញបច្ចេកទេសផលិតកម្មស្រូវពូជ បានរៀបចំក្នុងខែធ្នូ ឆ្នាំ២០១២ ធ្វើនៅទីតាំងបង្ហាញផលិតពូជចំនួន ២កន្លែង ។ ពិធីបូកសរុបទី ១ បានរៀបចំ នៅ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ នៅភូមិ សំបូរ ឃុំ សូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលមានការចូលរួម ពីថ្នាក់ដឹកនាំមន្ទីរកសិកម្មខេត្តកំពង់ចាម និង មន្ត្រីមន្ទីរកសិកម្មខេត្ត និង កសិកម្មស្រុក ព្រមទាំង ប្រជាកសិករ និង អាជ្ញាធរមូលដ្ឋាន ។

# ៦. ការកត់ត្រាចំណាយចំណូលផលិតកម្ម និង វិភាគសេដ្ឋកិច្ច

## *៦.១. ការកត់ត្រាចំណាយចំណូលផលិតកម្ម*

ការកត់ត្រាទុកនូវតួរលេខចំណាយចំណូល មានសារៈសំខាន់ណាស់ ។ មានហេតុផលជាច្រើន ដែលគេចាំបាច់ត្រូវកត់ត្រាជាប្រចាំ ពីចំណាយចំណូលផលិតកម្ម ។ ខាងក្រោម ជាហេតុផលចំបងៗមួយចំនួន ៖

- ប្រសិនបើគ្មានការកត់ត្រាពីអ្វីដែលត្រូវបានចំណាយ ហើយអ្វីដែលបានចំណូលនោះទេ យើងនឹងមិនអាចដឹងបានទេ ថាតើ មុខជំនួញរបស់យើងខាត ឬ ចំណេញ? ចូរចងចាំថា ការទទួលបានប្រាក់ចំណូលរាល់ថ្ងៃ មិនមានន័យថា យើងបានទទួលប្រាក់ចំណេញនោះទេ ។
- ប្រសិនបើយើងដឹងច្បាស់ពីមុខចំណាយ និង មុខចំណូលច្បាស់លាស់ យើងអាចរិះរកវិធីដើម្បីគ្រប់គ្រងជំនួញ ឱ្យបានកាន់តែល្អ កាន់តែបានចំណេញច្រើន។
- កំណត់ត្រាអាចត្រូវប្រើប្រាស់សម្រាប់ធ្វើផែនការចំណាយនៅពេលអនាគត ព្រោះយើងអាចដឹងពីតំលៃ និង ធនធានដែលត្រូវចំណាយ ។

គោលដៅចំបងនៃធ្វើជំនួញ ឬ ផលិតកម្មអ្វីមួយ គឺរកបានចំណេញ និង កាន់តែចំណេញច្រើន ។ ប្រាក់ចំណេញ ជា <u>ផលសង (ឬ គំលាតខុសគ្នាជាវិជ្ជមាន)</u> រវាង ប្រាក់ចំណូល (បានមកពីការលក់ផលិតផល ឬ សេវាកម្ម) និង **ប្រាក់ចំណាយទាំងអស់** ។ ចំណាយ អាចបែងចែកជា ២ ប្រភេទ គឺ ៖

(១) **ចំណាយថេរ** (មិនប្រែប្រួល [1]) គឺជា ចំណាយមូលធន ដូចជា ដី សំណង់ គ្រឿងចក្រ ឧបករណ៍កសិកម្ម ឃ្លាំង សម្ភារៈសាងសង់ទ្រើងត្រសក់ ប្រព័ន្ធស្រោចស្រពដំណក់ទឹក រោងបណ្ដុះផ្សិត ទ្រុងមាន់ គ្រឿងចក្រ...... ដែលមានតំលៃ (ត្រូវកាត់រំលស់) ជាប្រចាំ ទោះជាមានការផលិត ឬក៏ គ្មាន ក៏ដោយ ។ ដោយសារឧបករណ៍ និងសម្ភារៈ ក្នុងមុខចំណាយថេរទាំងនេះ អាចប្រើបានច្រើនដង (ប្រើម្ដង មិនអស់) ហើយ អាចប្រើនៅក្នុងផលិតកម្ម សារក្រោយៗទៀតនោះ គេត្រូវគិតរំលស់វា ជាច្រើនសារ/ដង ។ ការកំណត់ចំនួនសាររំលស់ថ្លៃឧបករណ៍ និង សម្ភារៈ ក្នុងប្រភេទចំណាយថេរនេះ អាចគិតបានច្រើនបែប ដូចជា តាម ចំនួនសារ (ដង) ផលិតកម្ម តាមអាយុកាល (រយៈពេល) អាចនៅប្រើបានរបស់វា ...... ។

[1] នៅពេលទិញ ឬសាងសងហើយ (គឺថា បានចំណាយហើយ) ទោះបីប្រើ ឬមិនប្រើក្ដី សម្រាប់ការផលិតទំនិញ (ផលិតផល) អ្វីមួយ ក៏ដោយ ក៏គុណភាព (គឺថា វាក្លាយបន្ដិចម្ដងៗ ទៅជារបស់ចាស់ សឹករេចរិល...... ) ហើយ តំលៃរបស់វា នឹងត្រូវបាត់បង់ បន្ដិចម្ដងៗ ទៅតាមនោះដែរ។

(២) **ចំណាយប្រែប្រួល** គឺជាប្រភេទចំណាយជាក់ស្តែងសម្រាប់ការផលិត ផលិតផល ឬសេវាកម្មអ្វីមួយ។ ការចំណាយប្រភេទនេះ រួមមាន វត្ថុធាតុដើម ដូចជា គ្រាប់ពូជ ជី ថ្នាំ កំបោរស ការរៀបចំដី ថ្លៃបូមទឹកស្រោចស្រព ពលកម្ម …… ដែលត្រូវការ ចាំបាច់សម្រាប់ផលិតរបស់ ឬផលិតផលអ្វីមួយ (ដូចជា ផ្សិតចំបើង មាន់ ជ្រូក……) ។

ដើម្បីឱ្យដឹងច្បាស់ ថាតើគោលដៅជោគជ័យជំនួញ សម្រេចបានត្រឹមណានោះ គេត្រូវការព័ត៌មានជាចាំបាច់ ដែលមិនអាចរកបាន ក្រៅតែពីការកត់ត្រាជាប្រចាំ និង បានត្រឹមត្រូវរបស់យើងនោះឡើយ ។ ការកត់ត្រា អាចផ្តោតលើការប្រមូលព័ត៌មានចាំបាច់ សម្រាប់វិភាគចំណាយ និង ចំណេញ និង តម្រង់ទិសមុខរបរ ឬ ផលិតកម្ម តាមពេលវេលា ឲ្យចំ ឆ្លើយតបតម្រូវការទីផ្សារ និង ទៅអនាគតខាងមុខ ។ ខាងក្រោមនេះ ជាទម្រង់កត់ត្រា[2] សាមញ្ញមួយ ដែលកសិករ (អ្នកផលិតស្រូវពូជ) អាចប្រើសម្រាប់កត់ត្រាចំណាយ ចំណូលរបស់ខ្លួន ។

ក. តារាងចំណាយ

ឈ្មោះផលិតកម្ម:…………………………………….

ថ្ងៃចាប់ផ្តើមផលិតកម្ម:……………………………….   ថ្ងៃបញ្ចប់ផលិតកម្ម:………………………

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

ខ. តារាងចំណូល

ឈ្មោះផលិតកម្ម:…………………………………….

ថ្ងៃចាប់ផ្តើមផលិតកម្ម:……………………………….   ថ្ងៃបញ្ចប់ផលិតកម្ម:………………………

| ល.រ | មុខចំណូល | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

[2] តាមគំរូ សៀវភៅកត់ត្រាគ្រប់គ្រងកសិដ្ឋានកសិករ របស់ គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាព ជុំវិញតំបន់ទន្លេសាប។

## ៦.២. ការប្រើប្រាស់ព័ត៌មានប្រមូលបាន សម្រាប់វិភាគចំណាយចំណូលផលិតកម្ម

ដើម្បីទទួលបានព័ត៌មាន ចាំបាច់ ត្រឹមត្រូវ គេត្រូវកំណត់ឲ្យបានច្បាស់ពីមុខចំណាយ និង ចំណូលទាំងអស់ ហើយកត់ត្រាបានជាប្រចាំ និង បានត្រឹមត្រូវពីព័ត៌មាន ដែលបានកំណត់ទាំងនោះ ។ ព័ត៌មានដែលប្រមូលបានទាំងនេះ នឹងត្រូវប្រើសម្រាប់ការវិភាគសេដ្ឋកិច្ច (គឺ ថ្លៃដើមផលិតផល និង ប្រាក់ចំណេញ) របស់ផលិតកម្មណាមួយ ។ ខាងក្រោមនេះ គឺជា គំរូកត់ត្រា និង វិភាគចំណាយ និង ចំណូលនៃផលិតកម្មស្រូវពូជ របស់ក្រុមកសិករផលិត ស្រូវពូជ នៅភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្ត កំពង់ចាម ។

### ការវិភាគសេដ្ឋកិច្ចផលិតកម្ម ស្រូវពូជ

ក្រុមកសិករ ភូមិ សំបូរ ឃុំ សូភាស ស្រុក ស្ទឹងត្រង់ ខេត្ត កំពង់ចាម

ដំណាំៈ ស្រូវពូជ ពូជៈ រាំងជ័យ

ថ្ងៃចាប់ផ្តើមៈ ថ្ងៃទី ០២ កក្កដា ២០១២ ថ្ងៃច្រូតកាត់ប្រមូលផល ថ្ងៃទី ១៨ ធ្នូ ២០១២

លើផ្ទៃដីៈ ១ហិកតា

| បរិយាយ | ឯកត្តា | ចំនួន | តម្លៃ/ឯកត្តា | សរុប | ចំនួនសារ វិលស់ | សរុប ក្នុង១រដូវ |
|---|---|---|---|---|---|---|
| **១-ចំណូល** | | | | | | |
| ក- ប្រាក់ចំណូលបានពីលក់ស្រូវពូជ | គីឡូក្រាម | 4,800 | 1.800 | 8.640.000 | - | 8.640.000 |
| ចំណូលសរុប | | 4.800 | | | | 8.640.000 |
| **២ក-ចំណាយ ប្រែប្រួល** | | | | | | |
| ថ្លៃរៀបចំដី (១ហិកតា) | សារ | 2 | 250.000 | 500.000 | - | 500.000 |
| គ្រាប់ពូជស្រូវ ( ២០គក្រ) | គីឡូក្រាម | 20 | 14.000 | 280.000 | - | 280.000 |
| ជីអិនប៉េកា/ជីគីមី (ប្រភេទ អ៊ុយរ៉េ និង ដេអាប៉េ) | គីឡូក្រាម | 240 | 2.500 | 600.000 | - | 600.000 |
| ជីធម្មជាតិ | គីឡូក្រាម | 1.000 | 50 | 50.000 | - | 50.000 |
| ថ្នាំកំចាត់សត្វកណ្តុរ | កញ្ចប់ | 20 | 2.000 | 40.000 | | 40.000 |
| ថ្នាំកំចាត់ជម្ងឺផ្សិត និងសត្វល្អិត | លីត្រ | 2 | 20.000 | 40.000 | - | 40.000 |
| កម្លាំងពលកម្មរៀបចំថ្នាលសំណាប | នាក់-ថ្ងៃ | 1 | 30.000 | 30.000 | - | 30.000 |

| | | | | | | |
|---|---|---|---|---|---|---|
| កម្លាំងពលកម្មសាបសំណាប | នាក់-ថ្ងៃ | 1 | 15.000 | 15.000 | | 15.000 |
| កម្លាំងពលកម្មដកសំណាប | នាក់-ថ្ងៃ | 10 | 15.000 | 150.000 | - | 150,000 |
| កម្លាំងពលកម្មស្ទូងស្រូវ | នាក់-ថ្ងៃ | 30 | 15.000 | 450.000 | - | 450.000 |
| កម្លាំងពលកម្មដកស្មៅ | នាក់-ថ្ងៃ | 12 | 15.000 | 180.000 | - | 180.000 |
| កម្លាំងពលកម្មដកពូជលាយ | នាក់-ថ្ងៃ | 9 | 15.000 | 135.000 | | 135.000 |
| កម្លាំងពលកម្មច្រូតស្រូវ | នាក់-ថ្ងៃ | 20 | 15.000 | 300.000 | | 300.000 |
| ឈ្នួលបោកបែន | សារ | 1 | 300.000 | 300.000 | | 300.000 |
| ឈ្នួលហាល សំអាត ច្រកខ្ទប់ | គីឡូក្រាម | 4.800 | 300 | 1.440.000 | | 1.440.000 |
| **សរុបចំណាយប្រែប្រួល (TVC)** | | | | | | **4.510.000** |
| *៣ក-ប្រាក់ចំណេញ ធៀប ចំណាយប្រែប្រួល TVC* | | | - | - | - | |
| **២ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | | |
| កៅស៊ូតង់ហាលស្រូវ | ផ្ទាំង | 6 | 100.000 | 600.000 | 20 | 30.000 |
| ម៉ាស៊ីនបក់សំអាតគ្រាប់ | គ្រឿង | 1 | 400.000 | 400.000 | 40 | 10.000 |
| ជញ្ជីង (១៥០ គក្រ ) | គ្រឿង | 1 | 200.000 | 200.000 | 40 | 5.000 |
| សំបកបាវមានបោះពុម្ព | សំបក | 600 | 1.000 | 600.000 | 1 | 600.000 |
| ម៉ាស៊ីនដេរមាត់បាវ | គ្រឿង | 1 | 140.000 | 140.000 | 30 | 4.666 |
| ប្រដាប់វាស់សំណើម | គ្រឿង | 1 | 1.080.000 | 1.080.000 | 40 | 27.000 |
| ធុងជ័រមានគម្របបិទជិត (២០០០លីត្រ) | ធុង | 1 | 780.000 | 780.000 | 40 | 19.500 |
| **សរុបចំណាយមិនប្រែប្រួល/ថេរ (TFC)** | | | | | | **696.166** |
| | | | | | | |
| **២គ-ចំណាយសរុប** ( TC = TVC+TFC ) | | | | | | **5.206.166** |
| *៣ខ-ប្រាក់ចំណេញ ធៀបចំណាយ សរុប TC* | | | | | | 3.433.834 |

# ឧបសម្ព័ន ១: សន្ទឹកគំរូកំណត់ត្រាចំណាយចំណូលផលិតកម្ម

(ស្រង់ពីកំណត់ត្រាកសិកររបស់គម្រោង TSTD)

ព័ត៌មានសម្រាប់ទំនាក់ទំនងប្រតិបត្តិករទីផ្សារ

| ល.រ | ឈ្មោះ | ភេទ | ទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| ក- អ្នកផលិត | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| ខ- អ្នកផ្គត់ផ្គង់សម្ភារៈ | | | |
| | | | |
| | | | |
| | | | |
| គ- អ្នកប្រមូលទិញ - លក់ | | | |
| | | | |
| | | | |
| | | | |
| | | | |
| ឃ- ផ្សេងៗ | | | |
| | | | |
| | | | |
| | | | |
| | | | |

## ១.បច្ចេកវិទ្យាបានរៀន

១-ឈ្មោះបច្ចេកវិទ្យា:........................................................................................................

គ្រូឧទ្ទេសនាម: ........................................................................................................

អាស័យដ្ឋានទាក់ទង: ........................................................................................................

កម្មវិធីសិក្សា:

| ថ្ងៃ-ខែ-ឆ្នាំ | សកម្មភាពសិក្សា | ផ្សេងៗ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

## ២. ប្រភេទផលិតកម្ម:..........................................................................

### ២-ក- ចំណាយផលិតកម្ម

ថ្ងៃចាប់ផ្តើម: ..........................................................................

ថ្ងៃបញ្ចប់ :..........................................................................

| ថ្ងៃ-ខែ | ឈ្មោះមុខទំនិញ | ឯកតា | ចំនួន | តម្លៃ/ឯកត្តា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | សរុបពលកម្ម | | | | |
| | | | | | |

### ២-ខ-ចំណូលផលិតកម្ម

| ថ្ងៃ-ខែប្រមូលផល | ឯកតា | ចំនួន | តម្លៃ-ឯកត្តា | ទឹកប្រាក់សរុប |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# ឧបសម្ព័ន ២: បញ្ជីរាយនាមអ្នកពាក់ព័ន្ធទំនាក់ទំនងសង្វាក់ទីផ្សារស្រូវពូជ

| ល.រ | ឈ្មោះ | ភេទ | អាសយដ្ឋាន | លេខទូរស័ព្ទ |
|---|---|---|---|---|
| ក. ក្រុមផលិតស្រូវពូជ | | | | |
| ១ | ប៊ួយ កេង | ប | ភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្ត កំពង់ចាម | 092 204 535 |
| ២ | ឈឹម ស្រ៊ុន | ស | ភូមិដូនតោ ឃុំ សំពងជ័យ ស្រុកជើងព្រៃ ខេត្ត កំពង់ចាម | 089 412 149 |
| ៣ | គង់ តូ | ប | ភូមិ អង្គរក្រៅ ឃុំដូនតី ស្រុក ពញាក្រែក ខេត្ត កំពង់ចាម | 097 789 8009 |
| ៤ | មាស វិបុល | ប | ភូមិ ត្រពាំងស្នៀង ឃុំកក់ ស្រុក ពញាក្រែក ខេត្ត កំពង់ចាម | 078 983861 |
| ៥ | សាម ស្រ៊ន់ | ប | ភូមិ ទៀមចាស់ ឃុំ កំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ | 097 7447948 |
| ៦ | ស៊ាន សឿន | ប | ភូមិ ខ្វែក ឃុំ កំពង់ថ្ម ស្រុកបារាយ ខេត្តកំពង់ធំ | 077 598 461 |
| ៧ | ផ្លោក បើម | ប | ភូមិ ប្រាសាទ ឃុំ សំរោងយា ស្រុកពួក ខេត្តសៀមរាប | 097 5611118 |
| ៨ | នឿន ណម | ប | ភូមិ ជ្រាវ ឃុំ ជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប | 012 86 5548 |
| ៩ | សួន មាន | ប | ភូមិ បត់ត្រង់ ឃុំ បត់ត្រង់ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ | 077 727 390 |
| ១០ | ផាយ សាគុណ | ប | ភូមិតាវង ឃុំ ពន្លៃ ស្រុក ភ្នំស្រុក ខេត្តបន្ទាយមានជ័យ | 097 3861265 |
| ១១ | យ៉ាន សុខន | ប | ភូមិ បត់ត្រង់ ឃុំ សំរោង ស្រុក អូរជ្រៅ ខេត្តបន្ទាយមានជ័យ | 092 846 493 |
| ខ. អ្នកផ្គត់ផ្គង់សម្ភារ: | | | | |
| ១ | ហ៊ុន យ៉ាដាណា | ប | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី CARDI) | 012 976 417 |
| ២ | ស៊ុន សុភី (ចែ ភី) | ស | ផ្សារចំការគរ ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ (តូបលេខ ៥៥៤ –៥៥៥) (ស្តៃ ខៀវ) | 092 540 034<br>012 558 396 |
| ៣ | តែម សេង<br>ផ្ទះលេខ ៤៨<br>ផ្សារខេត្ត កំពង់ធំ | ប | ផ្ទះលេខ ៤៨ ផ្សារទីរួមខេត្ត កំពង់ធំ<br>សាខាចែកចាយក្រុមហ៊ុន MALY SAN Group<br>ប្រចាំខេត្ត កំពង់ធំ | 012 838 343 |
| ៤ | អុង ឆៃ អន<br>តូបលេខ ៤៥<br>ផ្សារខេត្ត កំពង់ចាម | ប | តូប ៤៥ ផ្សារ ទីរួមខេត្តកំពង់ចាម<br>សាខាចែកចាយ ក្រុមហ៊ុន MALY SAN Group<br>ប្រចាំខេត្ត កំពង់ចាម | 012 834 939 |

# ឯកសារយោង

១-សៀវភៅបង្កុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ
២-ពូជស្រូវ និងបច្ចេកទេសដាំដុះ
៣-ដំណាំស្រូវនៅកម្ពុជា
៤-កិច្ចការប្រតិបត្តិបច្ចេកទេសក្រោយពេលប្រមូលផល

